# ព្រះរាជក្រឹត្យ

នស/រកត/០៧០១/២៨២

ស្តីពី

របបសញ្ញារដ្ឋបាល សញ្ញាសក្តិ និងឯកសណ្ឋានមន្ត្រី

នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីក្រមការ

## យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ, និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៣៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៩៦ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំពីនាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០១ ។

# ត្រាស់បង្គាប់

## ជំពូក ទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ៈ—**

ត្រូវបានបង្កើតរូបសញ្ញារដ្ឋបាល សញ្ញាស័ក្តិនិងឯកសណ្ឋានសំរាប់សំគាល់មន្ត្រីរាជការ ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីក្រមការដែលបំរើការងារតាមក្រសួងស្ថាប័ននានា នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២ ៈ—**

សញ្ញាស័ក្តិ និងឯកសណ្ឋាននេះ សំរាប់ប្រើប្រាស់នៅពេលចូលរួមពិធីបុណ្យប្រពៃណីជាតិ ពិធីបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗ ។

## ជំពូក ទី ២
## រូបសញ្ញារដ្ឋបាល

**មាត្រា៣ ៈ—**

រូបសញ្ញារដ្ឋបាលនេះត្រូវបានកំណត់ដូចតទៅ ៖

-មានរាងពងក្រពើ

-នៅខាងក្រោមចំកណ្តាល មានក្បាច់អង្គរ និងមានសន្លឹកភ្ញីទេសពីរជួរ រាងជាស្លែងក្របីទ្រជើងពាន

-មានជើងពានមួយទ្រសៀវភៅច្បាប់ បើកចំពាក់កណ្តាលនៅពីលើសន្លឹកភ្ញីទេស

-លើសៀវភៅច្បាប់បើកចំពាក់កណ្តាលនេះ មានមកុដរាជ្យ និងនៅលើមកុដរាជ្យ មានកាំរស្មីចំនួន ២៥ កាំ ។

រូបសញ្ញារដ្ឋបាលនេះ សំរាប់ដាក់នៅលើស័ក្តិស្មា ស័ក្តិចុងកអាវនៃមន្ត្រីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីក្រមការ និងដាក់នៅលើស័ក្តិខ្ទាស់លើអាវបុរស ឬលើក្រមាពាក់នារបស់នារី ដែលជាមន្ត្រីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ។

រូបសញ្ញារដ្ឋបាលនេះ មានរូបភាពដូចក្នុងឧបសម្ព័ន្ធទី ១ ។

## ជំពូក ទី ៣
## សញ្ញាស័ក្តិ

**មាត្រា៤ ៈ—**

សញ្ញាស័ក្តិមន្ត្រីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីក្រមការ ត្រូវបានកំណត់ដូចតទៅ ៖

ក-ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ៖

### ១.អំពីស័ក្តិស្មា

ស័ក្តិស្មាមានផ្ទៃកម្ពីពណ៌ខៀវចាស់ រចនាតុបតែងដោយក្បាច់កូរស្រូវពណ៌មាស និងក្បាច់សន្ទឹកភ្ញីទេសពណ៌មាសដាក់ខ្វែងគ្នា ហើយនៅពីលើក្បាច់ទាំងពីរនេះ មានរូបសញ្ញារដ្ឋបាលពណ៌មាស និងនៅពីលើខាងរូបសញ្ញារដ្ឋបាល មានឡេវរូបព្រះសង្ហារពណ៌មាសមួយ ។ បន្ទាប់មកមានបន្ទះក្បាច់ផ្ញេញក្របីពណ៌មាសព័ទ្ធជុំវិញក្តុងឋាន ។ ផ្ទៃខាងក្រៅនៃក្បាច់ផ្ញេញក្របីនេះ មានខ្សែពួរវេញព័ទ្ធជុំវិញពណ៌មាសបីខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិឧត្តមមន្ត្រី ពីរខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិវរៈមន្ត្រី និងមួយខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិអនុមន្ត្រី ។

ខ្នាតស័ក្តិស្មាត្រូវបានកំណត់ដូចខាងក្រោម ÷

| | | |
|---|---|---|
| -បាតក្រោម | ប្រវែង ៦ | សង្ទីម៉ែត្រ |
| -ទទឹងមុខកាត់ផ្នែកខាងលើ | ប្រវែង ៤.៤០ | សង្ទីម៉ែត្រ មានរាងកោងជាមុំទាល |
| -បណ្តោយពីលើដល់បាតក្រោម | ប្រវែង ១៣ | សង្ទីម៉ែត្រ |

### ២.អំពីស័ក្តិចុងកអាវ

ស័ក្តិចុងកអាវមានផ្ទៃកម្ពីពណ៌ខៀវចាស់ រចនាតុបតែងដោយក្បាច់កូរស្រូវពណ៌មាស និងក្បាច់សន្ទឹកភ្ញីទេសពណ៌មាសដាក់ខ្វែងគ្នា ហើយមានរូបសញ្ញារដ្ឋបាលពណ៌មាសនៅពីខាងមុខ ។ បន្ទាប់មកមានបន្ទះក្បាច់ផ្ញេញក្របីពណ៌មាសព័ទ្ធជុំវិញ និងមានខ្សែពួរវេញពណ៌មាសនៅផ្នែកខាងលើភ្ជាប់ជាមួយចំហៀងខាងមុខ បីខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិឧត្តមមន្ត្រី ពីរខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិវរៈមន្ត្រី និងមួយខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិអនុមន្ត្រី ។

ខ្នាតស័ក្តិចុងកអាវត្រូវបានកំណត់ដូចខាងក្រោម ÷

-មានរាងជាប្រលេឡូក្រាម

| | | |
|---|---|---|
| -បណ្តោយ | ប្រវែង ៩ | សង្ទីម៉ែត្រ |
| -ទទឹង | ប្រវែង ៣.៨ | សង្ទីម៉ែត្រ |

### ៣.អំពីស័ក្តិចុងដៃអាវទាំងសងខាង

ស័ក្តិចុងដៃអាវ មានផ្ទៃកម្ពីពណ៌ខៀវចាស់ រចនាតុបតែងដោយក្បាច់ភ្ញីទេសពណ៌មាស និងមានក្បាច់កូរស្រូវពណ៌មាសមួយនៅខាងចុង ហើយក្បាច់កូរស្រូវមួយទៀតខ្វែងនឹងគល់ក្បាច់ភ្ញីទេស ។ បន្ទាប់មកមានបន្ទះក្បាច់ផ្ញេញក្របីពណ៌មាសនៅជាយផ្នែកខាងលើ និងផ្នែកសងខាង ។ ផ្ទៃខាងក្រៅនៃក្បាច់ផ្ញេញក្របីនេះ មានខ្សែពួរវេញពណ៌មាសនៅផ្នែកខាងលើ និងផ្នែកចំហៀងទាំងសងខាង បីខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិឧត្តមមន្ត្រី ពីរខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិវរៈមន្ត្រី និងមួយខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិអនុមន្ត្រី ។ នៅបាតក្រោមបង្អស់នៃសញ្ញាស័ក្តិចុងដៃអាវ មានខ្សែពួរវេញពណ៌មាសមួយខ្សែ ។

ខ្នាតនៃស័ក្តិចុងដៃអាវទាំងសងខាង ត្រូវបានកំណត់ដូចខាងក្រោម ÷

-មានរាងបួនជ្រុងទ្រវែង

-បណ្តោយ ប្រវែង ៣២ សង្ទីម៉ែត្រ ៩.៦ .

-ទទឹង ប្រវែង ៩ សង្ទីម៉ែត្រ

រូបសញ្ញាស័ក្តិស្មា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវទាំងសងខាងសំរាប់មន្ត្រី ÷

-ឋានន្តរស័ក្តិឧត្តមមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី ២

-ឋានន្តរស័ក្តិវរៈមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី ៣

-ឋានន្តរស័ក្តិអនុមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី ៤ នៃព្រះរាជក្រឹត្យនេះ ។

ដោយឡែកស័ក្តិស្មា ស័ក្តិចុងកអាវ និងស័ក្តិចុងដៃអាវទាំងសងខាងសំរាប់នារី មានទំហំដូចខាងក្រោមនេះ ÷

-ចំពោះស័ក្តិស្មា អាចមានទំហំ ៨០ % ៨៥ % ៩០ % នៃទំហំស័ក្តិស្មារបស់បុរស អាស្រ័យលើមាឌរបស់នារី

-ស័ក្តិចុងដៃអាវ អាចមានទំហំទទឹងស្មើនឹង ៧០ % ទៅ ៧៥ % នៃទំហំទទឹងស័ក្តិចុងដៃអាវរបស់បុរស អាស្រ័យលើមាឌរបស់នារី

-ស័ក្តិកអាវ មានទំហំទទឹង ៣ សង្ទីម៉ែត្រ ទៅ ៣.៥ សង្ទីម៉ែត្រ អាស្រ័យលើកំពស់ករបស់នារី ។

**៤-អំពីស័ក្តិខ្ទាស់លើអាវសំរាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល**

ស័ក្តិខ្ទាស់លើអាវសំរាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល មានរាងសាជី ដែលបាតក្រោមមានរាងពងក្រពើ និងកំពូលរាងជ្រលម កំពស់ ៦០ សង្ទីម៉ែត្រ ទទឹង ៩០ សង្ទីម៉ែត្រ ។ ផ្ទៃកខាងក្នុងមានរូបសញ្ញារដ្ឋបាលពណ៌មាស បន្ទាប់មកមានក្បាច់ផ្ញេក្របិពហ៍មាសមួយព័ទ្ធអមផង ។ ផ្ទៃកខាងក្រៅមានខ្សែពួរវេញព័ទ្ធអមពណ៌មាសបីខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិឧត្តមមន្ត្រី ពីរខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិវរៈមន្ត្រី និងមួយខ្សែសំរាប់សំគាល់ឋានន្តរស័ក្តិអនុមន្ត្រី ។

ស័ក្តិខ្ទាស់លើអាវនេះ សំរាប់ខ្ទាស់លើអាវនៅពេលបំពេញការងារ ។ ស័ក្តិនេះក៏សំរាប់ខ្ទាស់លើក្រមាពានានារី ក្នុងឯកសណ្ឋានប្រពៃណី ។

រូបគំនូរស័ក្តិខ្ទាស់លើអាវ និងលើក្រមាពានាសំរាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល មានដូចក្នុងឧបសម្ព័ន្ធទី ៥ នៃព្រះរាជក្រឹត្យនេះ ។

**ខ-<u>ក្របខ័ណ្ឌមន្ត្រីក្រមការ</u>**

សញ្ញាស័ក្តិសំរាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីក្រមការ មានសណ្ឋានរូបភាព និងមានការកំណត់បែងចែកទៅតាមប្រភេទឋានន្តរស័ក្តិ ដូចសញ្ញាស័ក្តិមន្ត្រីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលដែរ ប៉ុន្តែខុសគ្នាត្រង់សញ្ញាស័ក្តិសំរាប់ក្របខ័ណ្ឌមន្ត្រីក្រមការមានពណ៌ប្រាក់ ។

រូបសញ្ញាស័ក្តិស្មា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវទាំងសងខាងសំរាប់មន្ត្រី ÷

-ឋានន្តរស័ក្តិនាយក្រមការ មានដូចក្នុងឧបសម្ព័ន្ធទី ៦

-ឋានន្តរស័ក្តិក្រមការដើមខ្សែ មានដូចក្នុងឧបសម្ព័ន្ធទី ៧

-និងឋានន្តរស័ក្តិក្រមការ មានដូចក្នុងឧបសម្ព័ន្ធទី ៨ នៃព្រះរាជក្រឹត្យនេះ ។/.

## ជំពូកទី ៤
## ប្រភេទឯកសណ្ឋាន និង ការប្រើប្រាស់

**មាត្រា៥** —

ប្រភេទឯកសណ្ឋានសំរាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីក្រមការ ត្រូវបានកំណត់ដូចខាងក្រោម ÷

**ក_ឯកសណ្ឋានផ្លូវការ**

**១_ចំពោះបុរស**

-អាវកុដពណ៌ស កត្រង់ ដៃវែង កាត់រាងអាវធំ មានបន្ទះលើស្មាសំរាប់ដាក់ស័ក្តិ និងគ្មានផែកខ្នង ។ អាវនេះមានហោប៉ៅចំនួនបួន គឺហោប៉ៅខាងលើពីរដេរបង្កប់ មានគំរបរាងបួនជ្រុងទ្រវែងមានតែមរាងមូល ហោប៉ៅខាងក្រោមពីរដេរបង្កប់ មានគំរបរាងបួនជ្រុងទ្រវែងមានតែមរាងមូល ហើយនៅលើគំរបហោប៉ៅទាំងបួននោះ មានឡេវរូបព្រះសង្ហារពណ៌មាស ឬពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌ ។ នៅចុងដៃអាវទាំងសងខាងមានឡេវបញ្ឆោត ៣ រូបព្រះសង្ហារពណ៌មាស ឬពណ៌ប្រាក់ ទៅតាមក្របខ័ណ្ឌ ។ អាវកុដពណ៌សនេះមានឡេវរូបព្រះសង្ហារចំនួន ៧ ពណ៌មាស ឬពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌ ។

-ខោជើងវែងមានពណ៌ទឹកប៊ិចក្រម៉ៅ ស្បែកជើងឃ្លុបពណ៌ខ្មៅចងខ្សែ និងស្រោមជើងពណ៌ខ្មៅ ។

**២_ចំពោះស្ត្រី**

-អាវជិបរាងពណ៌ស ដោយប្រើសាច់ក្រណាត់ដូចឈុតអាវរបស់បុរស កតាំង អាវដៃវែងត្រឹមភ្លែកគោលដៃ គ្មានផែកខ្នង បិទឡេវមុខ ដាក់ឡេវរូបព្រះសង្ហារចំនួន ៥ ។ ចុងកអាវទាំងសងខាងមានស័ក្តិតាមឋានន្តរស័ក្តិ មានបន្ទះលើស្មាសំរាប់ដាក់ស័ក្តិ គ្មានហោប៉ៅ ចុងដៃអាវមានស័ក្តិតាមឋានន្តរស័ក្តិ ។

-សំពត់សំឡុយអំពីអន្លូញ មានឆ្នូតពណ៌ខៀវ និងពណ៌ខ្មៅ ដែលឆ្នូតនីមួយៗ មានទំហំ ១.៥ មីល្លីម៉ែត្រ មានសំរុងលើភ្លែកគោលនៃស្មងជើង ប្រវែងពី ១០ ទៅ ១៥ សង្ទីម៉ែត្រ អនុលោមទៅតាមមាឌ និងកំពស់ ។

-ស្បែកជើងឃ្លុបមុខ ឃ្លុបក្រោយ មានកែង ពណ៌សសំរាប់ពេលព្រឹក ឬពណ៌ខ្មៅសំរាប់ពេលល្ងាច ។

រូបគំនូរឯកសណ្ឋានផ្លូវការសំរាប់បុរស និងស្ត្រីមានគំរូដូចក្នុងឧបសម្ព័ន្ធទី ៩ នៃព្រះរាជក្រឹត្យនេះ ។

**ខ_ឯកសណ្ឋានប្រពៃណីជាតិ**

**១_ចំពោះបុរស**

-អាវកុដពណ៌ស កត្រង់ដៃវែង កាត់រាងអាវធំ មានបន្ទះលើស្មាសំរាប់ដាក់ស័ក្តិ និងគ្មានផែកខ្នង ។ អាវនេះមានហោប៉ៅចំនួនបួន គឺហោប៉ៅខាងលើពីរដេរបង្កប់ មានគំរបរាងបួនជ្រុងទ្រវែងមានតែមរាងមូល ហោប៉ៅខាងក្រោមពីរដេរបង្កប់ មានគំរបរាងបួនជ្រុងទ្រវែងមានតែមរាងមូល ហើយនៅលើគំរបហោប៉ៅទាំង ព.ទ.

បូននោះ មានឡេវរូបព្រះសង្ហារពណ៌មាស ។ នៅចុងដៃអាវទាំងសងខាង មានឡេវបញ្ចោត ៣ រូបព្រះសង្ហារពណ៌មាស ។ អាវកុដពណ៌សនេះ មានឡេវរូបព្រះសង្ហារចំនួន ៧ ពណ៌មាស ។

-សំពត់ផាមួងចងក្បិន ពណ៌តាមថ្ងៃ ។

-ស្បែកជើងឃ្លុប ពណ៌ខ្មៅ កខ្វី មានចងខ្សែ ស្រោមជើងពណ៌ខ្មៅដល់ក្បាលជង្គង់ ។

## ២-ចំពោះស្ត្រី

-សំពត់ផាមួងចងក្បិន ពណ៌តាមថ្ងៃ ពាក់ជាមួយអាវពណ៌ស មានកមូល ដៃវែង និងមានស័ក្តិនៅចុងដៃអាវ

-ពាក់ក្រមាតាមពណ៌សំពត់ ឬពាក់ក្រមាពណ៌ស៊ីទ្រូន [១] តាមពិធីការកំណត់

-នៅលើក្រមាពាក់ផ្នែកខាងឆ្វេងនៃដើមទ្រូង មានខ្ចាស់សញ្ញាសំគាល់ឋានន្តរស័ក្តិឧត្តមមន្ត្រី

-ស្បែកជើងឃ្លុបមុខ ឃ្លុបក្រោយ មានកែង ពណ៌សសំរាប់ពេលព្រឹក ឬពណ៌ខ្មៅសំរាប់ពេលល្ងាច

-កាបូបយួរដៃពណ៌ស ឬពណ៌ខ្មៅ ( មិនអោយស្ពាយទេ ) ស្របតាមការប្រើស្បែកជើងពណ៌ស ឬពណ៌ខ្មៅ ។

រូបគំនូរឯកសណ្ឋានប្រពៃណីជាតិសំរាប់បុរស និងស្ត្រីដែលស្លៀកសំពត់ផាមួងចងក្បិន មានគំរូដូចក្នុងឧបសម្ព័ន្ធទី ១០ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា៦ .—**

ការប្រើប្រាស់ឯកសណ្ឋានសំរាប់មន្ត្រីគ្រប់គ្រងរដ្ឋបាល និងមន្ត្រីក្រមការ ត្រូវបានកំណត់ដូចខាងក្រោម ÷

-ឯកសណ្ឋានផ្លូវការសំរាប់ប្រើប្រាស់ក្នុងឱកាសទិវាបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗ ។

-ចំពោះឯកសណ្ឋានប្រពៃណីជាតិសំរាប់ប្រើប្រាស់ក្នុងទិវាបុណ្យប្រពៃណីជាតិ និងសាសនា ដែលប្រារព្ធធ្វើឡើងនៅក្នុងព្រះបរមរាជវាំង ក្នុងវត្តអារាម ឬទីកន្លែងផ្សេងៗ ត្រូវបានកំណត់អោយប្រើឯកសណ្ឋាននេះ តែមន្ត្រីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលដែលមានឋានន្តរស័ក្តិជាឧត្តមមន្ត្រី ។

## ជំពូកទី ៥

## របបកំណត់ឯកសណ្ឋាន និងសញ្ញាស័ក្តិ

**មាត្រា៧ .—**

ត្រូវបានផ្តល់ជូនដល់មន្ត្រីម្នាក់ៗ នូវឯកសណ្ឋានផ្លូវការ ឯកសណ្ឋានប្រពៃណីជាតិ សញ្ញាស័ក្តិ និងសំភារៈផ្សេងៗទៀត ដូចបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ មួយសំរាប់ សំរាប់ប្រើប្រាស់រយៈពេល បី ឆ្នាំម្តង ។ ល។

(១) ពណ៌ស៊ីទ្រូន : សម្បុរសលាយលឿងខ្ចីបន្តិច ១ សម្បុរលឿងខ្ចីបំផុត

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា៨ .—**

បទប្បញ្ញត្តិណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។ ន.រ.

**មាត្រា៩ .—**

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា នេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
នៃព្រះរាជាណាចក្រកម្ពុជា សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ: ១៥៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង តាន់**

ឧបសម្ព័ន្ធទី ១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៩២
ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០១ ស្តីពីសញ្ញាស័ក្តិ និងឯកសណ្ឋាន
មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីក្រមការ



# រូបសញ្ញារដ្ឋបាល

## សញ្ញាស័ក្តិមន្ត្រី ថ្នាក់ឧត្តមមន្ត្រី (ពណ៌មាស)



ស័ក្តិករអាវ



ស័ក្តិផ្ទាំងស្មា









ឧបសម្ព័ន្ធ ៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៦៤
ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០១ ស្ដីពីសញ្ញាស័ក្តិ និងឯកសណ្ឋាន
មន្ត្រីរាជការ... និងក្រុមប្រឹក្សា...

# សញ្ញាស័ក្តិមន្ត្រី ឋានន្តរស័ក្តិអនុមន្ត្រី (ពណ៌មាស)

ស័ក្តិករអាវ




ស័ក្តិខាងស្មា







ស័ក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៩២
ចុះថ្ងៃទី២៥ ខែកក្កដាឆ្នាំ២០០១ស្តីពីសញ្ញាស័ក្តិ និងឯកសណ្ឋាន
មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីក្រមការ

# ស័ក្តិខ្នាស់លើអាវសំរាប់មន្ត្រី
# នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល (ពណ៌មាស)



សំរាប់ឋានន្តរស័ក្តិឧត្តមមន្ត្រី



សំរាប់ឋានន្តរស័ក្តិវរៈមន្ត្រី



សំរាប់ឋានន្តរស័ក្តិអនុមន្ត្រី

[illegible] (ពណ៌ខ្មៅ)



ស័ក្តិកអាវ



ស័ក្តិបានស្មា



ស័ក្តិចុងដៃអាវ

[illegible]



ស័ក្តិកអាវ



ស័ក្តិថានស្មា



ស័ក្តិចុងដៃអាវ

សញ្ញាសក្តិមន្ត្រី ថ្នាក់ឧត្តមសេនីយ៍ក្រមភា: (ពណ៌ប្រាក់)



សក្តិកអាវ



សំក្តិឃានស្មា



# ប្រព័ន្ធឯកសណ្ឋានផ្លូវការ សំរាប់បុរស និងស្ត្រី



## រូបគំនូរឯកសណ្ឋានប្រពៃណីជាតិ សំរាប់បុរស និងស្ត្រី

